# ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

## លេខ ០៤១/០០៣/២០០១ កបធ.ច

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញ លិខិតប្រធានរដ្ឋសភាលេខ ០៧៤ រស ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្នើអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តយល់ព្រម កាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នា សម័យប្រជុំលើកទី ៥ នីតិកាលទី ២ ហើយព្រឹទ្ធសភា ក៏បានពិនិត្យចប់សព្វគ្រប់ នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំដដែល នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី១ ដោយបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង គ្មានការកែប្រែអ្វីឡើយ ហើយដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០១

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាម ច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។

-យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី២ ក្នុងការបញ្ជូនមកអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នេះត្រូវ ប្រកាសអោយប្រើ ។

-យល់ឃើញថា ទំរង់នៃការតាក់តែង និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ ។

-យល់ឃើញថា ខ្លឹមសារទាំង ១០ ជំពូក ដែលមាន ៩០ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ ។

**សំរេច**

**មាត្រា ១.-** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

ប្រធាន

ហត្ថលេខា និងត្រា

**ចាន់ សុត**

៙៙៙

## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ៨៣ អនក្រ.បក

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

----

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានមូលនិធិអភិវឌ្ឍន៍មុស្លិមកម្ពុជា